មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# វិចារណៈកថាព័ត៌មានរបស់ ម.ស.ម.ក

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៥

## ម.ស.ម.ក បារម្ភចំពោះការបង្ហាញឥទ្ធិពលហួសហេតុទៅលើចំណាត់ការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បារម្ភចំពោះការដកតំណែងអតីតប្រធានសាលាដំបូងរាជធានីភ្នំពេញ លោក អាំង មាលតី ដោយប្រញាប់ប្រញាល់ ចំពេលដែលមានការចោទប្រកាន់ជុំវិញករណីពុករលួយដែលវិធានការនេះធ្វើឡើងបន្ទាប់មានសេចក្តីសម្រេចដ៏ចម្រូងចម្រាសរបស់សាលាដំបូងក្នុងការដោះលែងឲ្យស្ថិតនៅក្រៅឃុំចំពោះករណីលោក ថោង ចំរើន និងអ្នកស្រី កែវ សារី ដែលជាឪពុកម្តាយរបស់ជនសង្ស័យជាឃាតករដែលត្រូវនគរបាលតាមចាប់ខ្លួនឈ្មោះថោង សារ៉ាត់។

ខណៈដែលមាត្រា ១៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបង្ហាញថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងមានអំណាចទាំងស្រុងក្នុងការសម្រេចផ្នែកវិធានការវិន័យ និងបញ្ឈប់មុខងាររបស់ចៅក្រម ការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលត្រូវបាន*កាសែតភ្នំពេញប៉ុស្តិ៍*រាយការណ៍ចុះផ្សាយនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ដែលមានចំណងជើងថា "លោក ហ៊ុន សែន រិះគន់ខ្លាំងៗទៅលើប្រធានចៅក្រម" ហាក់ដូចជាមានវិធានការភ្លាមៗពីសំណាក់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទៅលើចៅក្រមសាលាដំបូង លី សុខឡេង ដែល ជាចៅក្រមទទួលបន្ទុកសំណុំរឿងរបស់លោក ថោង សារ៉ាត់ និងទៅលើលោក អាំង មាលតី ប្រធានសាលាដំបូងរាជធានីភ្នំពេញ។ ជាការពិតណាស់ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ត្រូវបានរាយការណ៍ថាបានស្នើឲ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លោក អង្គ វង្សវឌ្ឍនា ធ្វើការស៊ើបអង្កេតទៅលើករណីនេះ និងចាត់វិធានការទៅលើចៅក្រមទាំងពីររូបនោះ។

អ្នកនាំពាក្យក្រសួងយុត្តិធម៌បានអះអាងថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបានបំពេញមុខងារយ៉ាងឯករាជ្យក្នុងសេចក្តីសម្រេចរបស់ខ្លួនដើម្បីផ្តួចផ្តើមធ្វើការស៊ើបអង្កេតទៅក្នុងករណីនេះ តែយ៉ាងណាក្តី នៅមានការបារម្ភយ៉ាងខ្លាំងទៅលើឥទ្ធិពលហួសហេតុនៃស្ថាប័ននីតិប្រតិបត្តិទៅលើការបំពេញមុខងាររបស់តុលាការ។ បន្ថែមពីលើនេះ ខណៈដែលករណីដែលពាក់ព័ន្ធទៅនឹងអំពើពុករលួយត្រូវតែចាត់វិធានការជាចាំបាច់ ក៏សង្ឃឹមផងដែរថា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងត្រូវត្រួតពិនិត្យមើលឲ្យបានប្រាកដប្រជា និងឥតលម្អៀងទៅលើភស្តុតាងដែលមាន ហើយមិនអើពើទៅលើសម្ពាធ និងការជ្រៀតជ្រែកផ្នែកនយោបាយណាមួយ។

ម.ស.ម.ក សូមរំលឹកផងដែរថា មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញ ចែងពីឯករាជ្យភាពរបស់ស្ថាប័នតុលាការ។ ម.ស.ម.ក កត់សម្គាល់ផងដែរថាអត្ថបទច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលទើបតែបានអនុម័ត

នាពេលកន្លងមកនេះ ពុំបានជានាដល់ឯករាជ្យភាព និងអព្យាក្រឹត្យភាពរបស់ស្ថាប័នតុលាការនោះទេ ដែលនេះជាការធ្វើឱ្យប៉ះពាល់ដល់ការបំពេញមុខងាររបស់ស្ថាប័នតុលាការ និងជាការធ្វើឱ្យស្ថាប័ននេះទទួលឥទ្ធិពលយ៉ាងខ្លាំងពីស្ថាប័ននីតិប្រតិបត្តិ។

**លោក សួន ប៊ុនធឿន អ្នកសម្របសម្រួលគម្រោងកំណែទម្រង់ប្រព័ន្ធតុលាការនៃ ម.ស.ម.ក មានប្រសាសន៍ថា ៖**

*"ទោះបីជាមានសញ្ញាបង្ហាញថាការដោះលែងលោក ថោង ចំរើន និងអ្នកស្រី កែវ សារី អាចបណ្តាលមកពីការអនុវត្តន៍ខុសនីតិវិធីនៅក្នុងតុលាការកម្ពុជាក្តី ក៏ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវតែជាស្ថាប័នឯករាជ្យ។ យើងខ្ញុំសង្ឃឹមថាអ្វីដែលយើងកំពុងឃើញនោះគឺជាឯករាជ្យភាពតុលាការពិតប្រាកដ មិនមានជាការឆ្លុះបញ្ចាំងពីការជ្រៀតជ្រែកហួសហេតុរបស់ស្ថាប័ននីតិប្រតិបត្តិទៅក្នុងស្ថាប័នតុលាការ។ យ៉ាងណាក៏ដោយ យើងខ្ញុំសូមស្វាគមន៍រាល់សញ្ញាវិជ្ជមាន និងមានទំនួលខុសត្រូវដែលនេះនឹងនាំទៅរកកំណែទម្រង់ប្រព័ន្ធតុលាការពិតប្រាកដ។"*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន ប៊ុនធឿន អ្នកសម្របសម្រួលគម្រោងកំណែទម្រង់ប្រព័ន្ធតុលាការ តាមទូរសព្ទ ៖ + ៨៥៥ (០) ១២ ៤៨ ៣៥ ៤៦ ឬអ៊ីម៉ែល៖** Bunthoueun@cchrcambodia.org **ឬ លោកស្រី ម៉ាតា រ៉ីហ្គី ទីប្រឹក្សារបស់ម.ស.ម.ក តាមទូរសព្ទ ៖ + ៨៥៥ (០) ១៣ ៥៩ ០៦ ៧១ ឬ អ៊ីម៉ែល៖** marta.riggio@cchrcambodia.org។

"ចប់"

**បណ្ណាធិការ ៖**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ដែលបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសាកលសម្រាប់សេរីភាពបញ្ចេញមតិ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការប្រឆាំងនឹងការធ្វើទារុណកម្ម ពិភពលោក (OMCT) ជាបណ្តាញជួយសង្គ្រោះចំពោះអំពើទារុណកម្ម និងជាសមាជិកនៃសម្ព័ន្ធសារព័ត៌មានអាស៊ីអគ្នេយ៍ (SEAPA) ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសង្គមព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងជ័យលាភីបានទទួលពានរង្វាន់ផ្នែកទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមប្រចាំឆ្នាំ២០១៣ ដែលផ្តល់ជូនដោយមជ្ឈមណ្ឌលទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៃសាកលវិទ្យាល័យឃ្វីនឡែន ក្នុងរដ្ឋប្រីសបែន ប្រទេសអូស្ត្រាលី។